ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

សភាជំនុំរដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខ　២០៨
ចុះថ្ងៃទី០៤ខែសីហាឆ្នាំ១៩៩៨
　　សាលដីកា
លេខ　៦២
ចុះថ្ងៃទី៣០ខែមិនាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើក សវនាការ ជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៩៩ ដោយមានសមាសភាព ដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | - | ឯកឧត្តម | ឌិត មុន្ទី | ប្រធាន |
| ២ | - | លោក | ប៉ែន ស៊ុន | ចៅក្រម |
| ៣ | - | លោក | ទេវុល មួន | ចៅក្រម |
| ៤ | - | លោក | ស៊ិន ឆឹម | ចៅក្រម |
| ៥ | - | លោន | ជីវ កេង | ចៅក្រមរបាយការណ៍ |

ក្រឡាបញ្ជី
លោក　ទៀង វុធ

តំណាងមហាអយ្យការ
លោក　ជួន ស៊ុនទៀង　ជាព្រះរាជអាជ្ញា

ដើម្បី ជំនុំជម្រះ លើបណ្តឹងសាទុក្ខពី សាលដីការដ្ឋប្បវេណីលេខ ១៥៥ ចុះថ្ងៃទី២០ ខែ-មេសា ឆ្នាំ១៩៩៨ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ៦៧៧ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ឆន សារុន ភេទប្រុស អាយុ ៣៧ សញ្ជាតិកម្ពុជា របរកសិ ធ្វើទាហានភូមិភាគ ២ ទីលំនៅ ភូមិទី ១៤ ឃុំ កំពង់ចាម ស្រុក កំពង់ចាម ខេត្តកំពង់ចាម ឪពុកឈ្មោះ នេត ឆន " ស " ម្តាយឈ្មោះ ស៊ុយ ទូច " រ " ។

និង ចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ប្រាក់ ស្រី ភេទប្រុស អាយុ ៥៣ឆ្នាំ សញ្ជាតិកម្ពុជា របរកសិ ប្រធានការិយាល័យមន្ទីរសាធារណៈការ ទីលំនៅ ភូមិ បឹងកុក ឃុំបឹងកុក ស្រុក -កំពង់ចាម ខេត្តកំពង់ចាម ឪពុកឈ្មោះ ប្រាក់ ឌួក " ស " ម្តាយឈ្មោះ ហ៊ត ឃឹម " រ " ។ ជាតំណាងអោយមន្ទីរសាធារណៈការ និង ដឹកជញ្ជូន ។

កម្មវត្ថុបណ្តឹង :　ប្តឹងសុំអោយរុះផ្ទះចេញពីដីរដ្ឋ ។

តាមពាក្យបណ្តឹងសាទុក្ខលេខ ២២៩ ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៨ របស់លោក ឆន សារ៉ុន បានប្តឹងមិនសុខចិត្តនឹង សាលដីកា របស់ សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេច ទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ២០៨ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៨ របស់

ល។

តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៥_ ៩_ ៨៥ ថាខ្លួនសុំអោយឈ្មោះ ឆន សារុន រុះរើផ្ទះចេញពីដីរដ្ឋ ដោយឈ្មោះ ឆន សារុន បានមកសុំដីនេះស្នាក់នៅបណ្តោះអាសន្នទំរាំរកដីរស់នៅបាន តែឈ្មោះនេះបែរជាវាតរបងចូលក្នុងដីរដ្ឋ ហើយវាយរបងរបស់មន្ទីរ ទំលាយធ្វើជាច្រកចេញចូលតាមទំនើងចិត្ត ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ០៦ " គ " ចុះថ្ងៃទី១៧ ខែកម្ភៈ ឆ្នាំ១៩៨៧ របស់ តុលាការខេត្ត កំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១ - ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ថន ឌឿន ប្រធាន សាធារណៈការ និង ដឹកជញ្ជូន ខេត្តកំពង់ចាម តំណាងមន្ទីរ សាធារណៈការ និង ដឹកជញ្ជូន ចុះថ្ងៃទី២៥ - ខែកញ្ញា ឆ្នាំ១៩៨៥ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់បញ្ជីសារពើភណ្ឌចុះថ្ងៃទី ០៦_ ០៨_ ៨៣ របស់មន្ទីរសាធារណៈ - និង ដឹកជញ្ជូន ខេត្តកំពង់ចាម ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣ - ទទួលស្គាល់តំណាងផ្ទេរសិទ្ធិឈ្មោះ ព្រាក់ ទ្រី ផ្ទាត់ណាងអោយមន្ទីរ សាធារណៈការ និង ដឹកជញ្ជូន ខេត្តកំពង់ចាម ទុកជាត្រឹមត្រូវតាមច្បាប់ ។

៥ - បង្គាប់អោយឈ្មោះ ឆន សារុន រុះផ្ទះចេញពីដីកើតហេតុ រយៈពេល - ០៦ ខែក្រោយពី សាលក្រម នេះចូលជាស្ថាពរ ។

៦ - អោយមន្ទីរសាធារណៈការ និង ដឹកជញ្ជូន ខេត្តកំពង់ចាម ចេញសោហ៊ុយរុះរើចំនួន ២០ម៉ឺនរៀល អោយទៅឈ្មោះ ឆន សារុន តាមការឯកភាពរបស់ប្រធាន - ស្តីទី មន្ទីរសាធារណៈការ និង ដឹកជញ្ជូន ខេត្តកំពង់ចាម ។

៧ - រឹបអូសប្រាក់ប្រដាប់ក្តី គឺ ពន្ធចុះបញ្ជីក្តី ពន្ធហ៊ឹង ១.៨០០០៛០០ ប្រាក់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛០០ ប្រាក់ប្រគល់ដីកាកោះ ៥.០០០៛០០ សរុប ៧.០០០៛០០ ប្រាក់នេះបានកាត់យកពីប្រាក់ ដែលដើមចោទបានបង់រួចហើយ នៅពេលដែលសាលក្រមនេះចូលជាស្ថាពរទើបបង្គាប់អោយចុងចម្លើយបង់សងវិញជាក្រោយ ។

៨ - សាលក្រមនេះ ប្រកាស ជាសាធារណៈ ចំពោះមុខតំណាងផ្ទេរសិទ្ធិឈ្មោះ ព្រាក់ ទ្រី និង ចុងចម្លើយឈ្មោះ ឆន សារុន ។ ភាគីណាមិនសុខចិត្តនឹងសាលក្រមនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១០_ ៥_ ៨៧ របស់សាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ១៥៥ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៨៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ ៖

១ - ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១០_ ៥_ ៨៧ របស់ឈ្មោះ ផាវ សំអាត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់ សាលក្រមលេខ ៦ " គ " ចុះថ្ងៃទី ១៧_ ២_ ៨៧ របស់ - តុលាការខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល ។

៣ - កាត់យកប្រាក់ប្រដាប់ក្តីនៅផ្សាន់ សាលាឧទ្ធរណ៍ ចំនួន ១៣.០០០៛០០

ដែលដើមបណ្ដឹងឧទ្ធរណ៍ បានបង់រួចហើយ គឺ ពន្ធចុះបញ្ជី និង ពន្ធហ៊ឹងចំនួន ២.៥៥០៛០០ រង្វាន់ក្រឡាបញ្ជីការពិបប្រាក់ ៤៥០៛០០ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛០០ និង ចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛០០ ។

៤ _ សាលដីកា នេះជំនុំជំរះ និង ប្រកាស ជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវ សាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងសាទុក្ខលេខ ២២៦ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៨ របស់ឈ្មោះ ឆន សារុន ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញ សារណា ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ឈ្មោះ ឆន សារុន
បានឃើញ សារណាឆ្លើយតបចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៨របស់ឈ្មោះ ប្រាក់ ទ្រី

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :
សាលដីកា របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈ ត្រឹមត្រូវតាមគតិច្បាប់ហើយ សូមក្រុមប្រឹក្សា ជំនុំជំរះ សំរេចតាមច្បាប់តទៅ ។

ក្រឡាបញ្ជីអានសារណា របស់ឈ្មោះ ឆន សារុន

លោក ប្រាក់ ទ្រី បានឆ្លើយថា ពីដើមគាត់ជាមន្ត្រីធ្វើការនៅចំការកៅស៊ូ ហើយក៏បានផ្លាស់មកធ្វើការនៅ មន្ទីរសាធារណៈការ ខេត្ត ពេលនោះគាត់គ្មានផ្ទះស្នាក់នៅ គាត់ក៏មកសុំដីរបស់មន្ទីរ ដើម្បីស្នាក់នៅជាបណ្ដោះអាសន្ន ដោយគាត់បានសង់ខ្ទមតូចមួយ ហើយសន្យាថាបើមន្ទីរត្រូវការវិញនៅពេលណាគាត់នឹងចុះចេញពីដីនេះភ្លាម ដល់ក្រោយមកគាត់ចេះតែពង្រីកផ្ទះកាន់តែធំ ដោយបំផ្លាញរបងរបស់មន្ទីរចោល ដើម្បីធ្វើច្រកចេញចូល ដល់រដ្ឋត្រូវការ បែរជាគាត់ពុំព្រមរុះរើផ្ទះចេញ ទោះបីមន្ទីរមានដីជូរអោយក៏ដោយ ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សារណា របស់លោក ឆន សារុន និង ចម្លើយរបស់លោក ប្រាក់ ទ្រី តំណាងមន្ទីរសាធារណៈការ ខេត្តកំពង់ចាម
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ២២៨ ចុះថ្ងៃទី ១២-៦-៩៨ របស់លោក ឆន សារុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមក ជំនុំជំរះ បានតាមមាត្រា ១៤ នៃ ច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការដែលលោក ឆន សារុន លើកឡើងនៅក្នុងសារណា ចុះថ្ងៃទី ១១-៩-៩៨ របស់លោកថា លោក ប៊ុន អេង និងលោក ប៊ុន សុខុម យល់ព្រមអោយលោកសង់ផ្ទះនៅលើដីទំនាស់ មិនមែនអោយនៅជាបណ្ដោះអាសន្ននោះគឺពុំមានលិខិតជាលាយលក្ខណ៍អក្សរណាមួយជាសំអាងទេ ហើយលោក ប៊ុន អេង និងលោក ប៊ុន សុខុម បានឆ្លើយ

នៅមុខ តុលាការ ថា លោកបានផ្តល់ដីអោយសង់ផ្ទះនៅបណ្តោះអាសន្ន មិនមែនអោយដាច់ទៀយពីព្រោះជាដីរបស់រដ្ឋ ។

- យល់ឃើញថា ការដែលលោក ឆន សារុន លើកឡើងក្នុងសារណារបស់លោកថា លោក បានរស់នៅលើដីទំនាស់អស់រយៈពេល ៦ឆ្នាំ ហើយដូច្នេះលោកមានសិទ្ធិលើដីនេះតាមមាត្រា ៦២ នៃច្បាប់ភូមិបាលហើយនោះ ជាការភន្តច្រឡំពីព្រោះដីទំនាស់នេះជាដីសាធារណៈ ដែលតាមមាត្រា ៥ នៃ ច្បាប់ភូមិបាល លោកពុំត្រូវបានទទួលជាកម្មសិទ្ធិឯកជនឡើយ ហើយម្យ៉ាងទៀតមន្ទីរ សាធារណៈការ និង ដឹកជញ្ជូនបានជូនដំណឹងអោយលោករុះរើផ្ទះចេញតាំងពីថ្ងៃទី ១១- ៨- ៩៣ និង បានប្តឹងតាំងពីថ្ងៃទី ២៤- ៩- ៩៤ មកម្ល៉េះ ដូចនេះបើគិតពីឆ្នាំ១៩៩១ ដែលលោក ឆន សារុន ស្នាក់នៅរហូតដល់ឆ្នាំ ១៩៩៤ ដែលដើមចោទប្តឹងមានរយៈពេលប្រហែល ៣ឆ្នាំប៉ុណ្ណោះ ។

- យល់ឃើញថា លោក ឆន សារុន បានផ្ញើសារណាការពារ រឿងក្តីរបស់លោកជូនមក តុលាការកំពូល រួចហើយប៉ុន្តែពុំបានមកចូលរួម សវនាការ នេះទេដូច្នេះ តុលាការកំពូល ជំនុំជំរះ រឿងនេះកំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៥៥ ចុះថ្ងៃទី ២០- ៤- ៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាម ទំរង់ និង គតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខតំណាងមន្ទីរសាធារណៈការ និង ដឹកជញ្ជូនខេត្តកំពង់ចាម កំបាំងមុខលោក ឆន សារុន ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ ២២៩ ចុះថ្ងៃទី ១២- ៦- ៩៨ របស់លោក ឆន សារុន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៥៥ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛០០ ដែលលោក ឆន សារុន បានបង់រួចហើយ គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛០០ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,
- ចំណាយលើកិច្ចប្រជុំដីកាកោះចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ។

បង្គាប់អោយ លោក ឆន សារុន បង់ពន្ធសមាមាត្រ មួយភាគរយ លើតម្លៃដីទំនាស់ និង បង្គាប់អោយ មន្ទីរសាធារណៈការ និង ដឹកជញ្ជូនខេត្តកំពង់ចាម បង់ពន្ធសមាមាត្រ មួយភាគរយ លើចំនួន ទឹកប្រាក់ ២០ ម៉ឺនរៀល ។

៤ - សាលដីកានេះ ប្រកាស នាសវនាការ ជាសាធារណៈ នៅថ្ងៃទី៣០ - ខែមីនា ឆ្នាំ១៩៩៩ ។